

# ជ្រុង ១ នៃទស្សនៈនយោបាយរបស់ព្រះមហាភិរម្យ

៦/៥/២០១៣

## ព្រះសង្ឃនិងការបោះឆ្នោត

**សិទ្ធិ**ជាធម្មភាពតាំងពីកំណើត កុលបុត្រខ្មែរឲ្យតែកើតមកតែងទទួលបានសិទ្ធិនេះខាងសង្គមនិងនយោបាយរហូតដល់អវសាននៃជីវិត **ព្រះសង្ឃ**បាត់ជាស្ថានភាពមួយរបស់បុគ្គលដែលសមាជិកក្នុងសង្គមឲ្យនិយមន័យថាជាឧត្តមភេទឬជាភេទខ្ពង់ខ្ពស់ បរិសុទ្ធ និងគួរឲ្យគោរពជាងភេទណា ៗ ក្នុងសង្គម ។

**សំណួរថា** *តើព្រះសង្ឃគួរបោះឆ្នោតឬទេ?*

កាលបើតាំងសំណួរនេះឡើង ប្រាកដជានឹងមានក្រុមអ្នកឆ្លើយសំណួរនេះដល់ទៅ ២ ក្រុម គឺ ក្រុមទី ១ ឆ្លើយថា គួរឲ្យព្រះសង្ឃបោះឆ្នោត និង ក្រុមទី ២ ឆ្លើយថា មិនគួរឲ្យព្រះសង្ឃបោះឆ្នោតទេ ។

ក្រុមទី ១ ដែលឆ្លើយថា គួរឲ្យព្រះសង្ឃបោះឆ្នោតនោះ គេសំអាងទៅលើរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រង់មាត្រា ៣៤ ថា *“ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត* ”និងមាត្រា ៣៥ ថា *“ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ”* ដែលផ្ដល់សិទ្ធិស្មើ ៗ គ្នាដល់សមាជិករបស់សង្គម

ឧទាហរណ៍ដូចជា ព្រះសង្ឃក្នុងប្រទេសសិរីលង្កាបង្កើតគណបក្សនយោបាយ ឬ ព្រះសង្ឃជប៉ុន ចូលរួមក្នុងនយោបាយ ឬថា ទីបេត៍មានព្រះសង្ឃជាអ្នកដឹកនាំនយោបាយ ជាដើម

ហើយថាប្រសិនបើមិនឲ្យសិទ្ធិបោះឆ្នោតដល់ព្រះសង្ឃទេ សម្ដែងថា កំពុងតែលុបបំបាត់សិទ្ធិតាំងពីកំណើតរបស់ព្រះសង្ឃដែលការនេះមិនមែនជារបបប្រជាធិបតេយ្យទេ ។

ក្រុមទី ២ ដែលឆ្លើយថា *មិនគួរឲ្យព្រះសង្ឃបោះឆ្នោតទេ* គេសំអាងហេតុផលថា ព្រះសង្ឃជាសមណៈដែលមានភារៈជាអ្នកស្ងប់មិនត្រូវចូលលាយឡំនឹងភាពច្របូកច្របល់ខាងនយោបាយទេ ព្រោះថា ការបោះឆ្នោតមិនមែនជាកិច្ចរបស់ព្រះសង្ឃដែលត្រូវធ្វើនោះទេ និងថា ការបោះឆ្នោតជាការបែងចែកបក្សពួកដែលមិនគួរឲ្យសមណៈចូលទៅឡូកឡំ ។

កាលបើត្រូវធ្វើដំណើរមកដល់ផ្លូវបំបែកជា ២ គឺ ផ្លូវទៅកាន់រដ្ឋធម្មនុញ្ញ និង ផ្លូវទៅកាន់បរិយធម៌ បែបនេះ ព្រះសង្ឃត្រូវគិតគន់យ៉ាងខ្លាំងទាំងពិបាកក្នុងការតម្កល់ឥរិយាបថផ្នែកនយោបាយទៀត ។

ប្រការនេះធ្វើឲ្យកើតសំណួរឡើងថា **រដ្ឋធម្មនុញ្ញ** និង **បរិយធម៌** តើមួយណាសំខាន់បំផុត?

បើសម្លឹងមើលចេញពីជ្រុងរបស់ព្រះសង្ឃ ឃើញថា **បរិយធម៌សំខាន់បំផុត** ប៉ុន្តែបើសម្លឹងមើលចេញពីជ្រុងមួយរបស់ប្រជាជន ឃើញថា **ធម្មនុញ្ញសំខាន់បំផុត** ។ ការសម្លឹងមើលចេញពីជ្រុងផ្សេងគ្នានេះឯងតែងធ្វើឲ្យបែកខ្ញែកផ្នែកទស្សនៈ ហើយទីបំផុត ភាគីទាំងសងក៏មិនអាចស្វែងរកចំណុចរួមបាន ។

ជម្លោះដែលកើតឡើងច្រើនតែកើតចេញពីការសម្លឹងមើលចេញពីជ្រុងផ្សេងគ្នានេះឯង ។

ដើម្បីផ្សាភ្ជាប់ជ្រុងទាំងសងខាងឲ្យជាប់គ្នា ប្រជាពលរដ្ឋខ្មែរទាំងព្រះសង្ឃទាំងឃរាវាស ត្រូវសម្លឹងមើលប្រយោជន៍សាធារណៈជាទីតាំង មិនត្រូវសម្លឹងមើលមកក្នុងក្រុមរបស់ខ្លួនឯងឡើយ ។

ប្រយោជន៍សាធារណៈចាត់ជាបំណុចរួមដែលភាគីទាំងសងខាងត្រូវប្រកាន់ខ្ជាប់និងចូលរួមយ៉ាងសកម្មដើម្បីជម្រុញប្រយោជន៍សាធារណៈនោះឲ្យកើតឡើងដល់គ្រប់ភាគី ។

ការដែលមានគណបក្សនយោបាយច្រើនចូលរួមក្នុងការបោះឆ្នោតចាត់ជាក្រុមមួយ ៗដែលរដ្ឋធម្មនុញ្ញតម្រូវឲ្យមាន ប្រៀបដូចជាក្រុមកីឡាករដែលនាំស្នើឲ្យប្រជាជនជ្រើសរើស ប៉ុន្តែសម្រាប់ព្រះសង្ឃអ្នកកាន់បរិយធម៌ហើយត្រូវការរក្សាភារៈជាអ្នកស្ងប់ស្ងៀម មិនគួរចូលរួមឬជាបំណែកសមាជិករបស់ក្រុមណានីមួយទេ ឬថា ចាត់ជាអគោចរសម្រាប់ព្រះសង្ឃ ព្រោះត្រូវការទប់ស្កាត់បរុប្បវាទសម្តីរិះគន់ពីក្រុមផ្សេងទៀតថាព្រះសង្ឃបានចូលរួមទៅក្នុងក្រុមមួយ ។

**ប្រយោជន៍សាធារណៈ** បានដល់ ផលប្រយោជន៍របស់សមាជិកទាំងអស់ក្នុងភូមិ ឃុំ ស្រុក ខេត្ត ឬ សង្គមទាំងមូល ឬថា ផលប្រយោជន៍របស់ប្រជាជននិងដើម្បីប្រជាជន ។

ព្រះសង្ឃអាចចូលរួមក្នុងប្រយោជន៍សាធារណៈបាន ដូចជា ការអនុរក្សសត្វព្រៃ ការអនុរក្សព្រៃឈើ ការថែរក្សាវប្បធម៌ ការសង្គ្រោះកុមារកំព្រា ការថែរក្សាបរិស្ថានធម្មជាតិ ការថែរក្សាប្រភពទឹក ការបង្ហាត់បង្រៀនប្រជាជនឲ្យយល់ពីសិទ្ធិសេរីភាពនិងតួនាទីរបស់ខ្លួន ការបណ្តុះបណ្តាលចំណេះវិជ្ជាទាំងផ្លូវលោកនិងផ្លូវធម៌ ការធ្វើធម្មយាត្រាដើម្បីសន្តិភាព ការធ្វើជាព្រះវិទ្យាចារ្យក្នុងស្ថាប័នអប់រំតាំងពីកម្រិតបឋម មធ្យម និង ឧត្តមសិក្សា មិនកំណត់ថាវិជ្ជាផ្លូវលោកឬផ្លូវធម៌ទេឲ្យតែព្រះសង្ឃមានចំណេះជំនាញអាចផ្តល់ជូនសង្គមបានទាំងសមាជិកសង្គមមិនត្រូវរើសអើងតួនាទីរបស់ព្រះសង្ឃឡើយ ព្រោះនេះជាការចូលរួមជួយសង្គមរបស់ព្រះសង្ឃរហូតដល់ការអប់រំនយោបាយដល់អ្នកនយោបាយក្នុងរដ្ឋសភាឲ្យស្គាល់បាបបុណ្យគុណទោសក្នុងការបដិបត្តិតួនាទីរបស់ខ្លួនជាដើម

ម្យ៉ាងទៀត ស្ថាប័នសង្ឃបាត់ជាស្ថាប័នកំពូលដែលត្រូវកំណត់តួនាទីរបស់ខ្លួនឲ្យបានច្បាស់លាស់ក្នុងការចូលរួមជួយសង្គម នៅពេលណាសង្គមមានអំពើហិង្សាជាទ្រង់ទ្រាយធំកើតឡើង ស្ថាប័នសង្ឃត្រូវបេញសង្ឃប្រកាសថ្កោលទោសអំពើហិង្សានោះទោះកើតបេញពីភាគីណាក៏ដោយ ព្រោះថា អំពើហិង្សាមិនមែនជាគោលបំណងរបស់ព្រះពុទ្ធសាសនាឡើយ ព្រះពុទ្ធសាសនាត្រូវការឲ្យប្រជាជនដោះស្រាយបញ្ហាដោយបញ្ញានិងសន្តិវិធី ។

មានសំណួរថា បើនយោបាយរបស់រដ្ឋាភិបាលធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ តើព្រះសង្ឃអាចចូលរួមជាមួយនឹងប្រជាជនទាមទារឲ្យរដ្ឋាភិបាលពិនិត្យមើលនយោបាយនោះឡើងវិញបានឬទេ?

ឆ្លើយថា បើរដ្ឋាភិបាលអនុវត្តនយោបាយធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ព្រះសង្ឃអាចចូលរួមរួមជាមួយនឹងប្រជាជនឬអាចធ្វើជាអ្នកតំណាងនាំសំណើរបស់ប្រជាជនជូនចំពោះអ្នកតំណាងរដ្ឋាភិបាលក៏បាន ហើយរដ្ឋាភិបាលមិនត្រូវសម្លឹងមើលអ្នកតំណាងដើម្បីប្រយោជន៍សាធារណៈក្នុងផ្លូវអវិជ្ជមាននោះទេ ផ្ទុយទៅវិញ ត្រូវជួយលើកទឹកចិត្តនិងការពារសុវត្ថិភាព ។

សរុបសេចក្តីមកថា ព្រះសង្ឃមិនគួរចូលរួមក្នុងបក្សពួកឬគណបក្សនយោបាយណាមួយទេ សូម្បីតែការបោះសន្លឹកឆ្នោតឬចូលជាសមាជិកនៃគណបក្សនយោបាយណាមួយឬឈរឈ្មោះឲ្យអ្នកដទៃបោះឆ្នោតឲ្យក៏ដោយ ព្រោះសិទ្ធិរបស់ព្រះសង្ឃដែលមានមកតាំងពីកំណើតដូចយ៉ាងមនុស្សទូទៅនោះត្រូវបានគូរបន្ទាត់ដោយបរិយធម៌ដែលសមាជិកក្នុងសង្គមឲ្យនិយមន័យថាជាឧត្តមភេទនិងជាភេទដែលគួរឲ្យគោរពជាងភេទណា ៗក្នុងសង្គម ប៉ុន្តែព្រះសង្ឃអាចចូលរួមក្នុងប្រយោជន៍សាធារណៈបានដែលសមស្របនឹងពុទ្ធតម្រាស់ថា **ចរថ ភិក្ខវេ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ** ប្រែថា *ព្រះសង្ឃអាចចូលរួមកសាងប្រយោជន៍សុខដល់ប្រជាជននិងសង្គមបាន។*

ទោះបីចម្លើយចេញមកក្នុងលក្ខណៈសង្កត់ធ្ងន់ផ្នែកបរិយាធម៌ក៏ដោយ ក៏មិនមែនមានន័យថា ចម្លើយនេះ ត្រឹមត្រូវមួយរយភាគរយនោះទេ ប៉ុន្តែត្រូវយល់ថា នេះជាចម្លើយមួយដែលមើលចេញពីជ្រុងនៃ បរិយធម៌ ។